ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០១៤

នៅក្នុងខែមករានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបើកទំព័រថ្មី លើការគ្រប់គ្រងវិន័យ និងការគ្រប់គ្រងការងារតាមបែបបទ និងនីតិវិធីការងារថ្មី និងបំពេញការងារយ៉ាងសកម្មពាក់ព័ន្ធនឹងដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គរបស់ព្រឹទ្ធសភា ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់នានា ការរៀបចំផ្លាស់ប្តូរអគារ បំពាក់និងពង្រីកមធ្យោបាយបន្ថែមក្នុងព្រឹទ្ធសភា ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើតសេវាថ្មីៗ ការកសាងគោលនយោបាយនានា ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

-បានចាត់ចែងរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា លើកទី២ នីតិកាលទី៣ ចំនួន០៣លើក និងរៀបចំធ្វើបទបង្ហាញស្តីពី "រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា" និងបានរៀបចំពិធីសម្ភោធអគារថ្មី០៣ខ្នង០៣ជាន់ ជាអំណោយរបស់រាជរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិនជូនដល់ព្រឹទ្ធសភា ប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ អន្តរជាតិ (ចិន ជប៉ុន) ចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗ ចំនួន៦២២ច្បាប់ ។

## ១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖

-បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ ។

## ២.សេវាទ្រទ្រង់មុខងារតំណាង៖

-បានរៀបចំវេទិកាសាធារណៈ ចំនួន០១លើក ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋនៅខេត្តក្រចេះ ស្តីពីការយល់ដឹង និងចាត់តាំងអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ គោលនយោបាយ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយ វិមជ្ឈការ វិសហមជ្ឈការ ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្តរាជធានីទូទាំងប្រទេស ចំនួន៨៩លើក ដើម្បីសំណេះសំណាល សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ ព្យាបាលជំងឺ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៩៨លើក ។

-ទទួលពាក្យបណ្តឹងចំនួន០១ករណី និងបានទទួលលិខិត ឆ្លើយតបពីក្រសួងយុត្តិធម៌ ចំនួន ០២ករណី ។

**៣.សេវាទ្រទ្រង់មុខងារព័ត៌មាន៖**

-បានអមដំណើរសមាជិក-សមាជិកាគណៈកម្មការនានា របស់ព្រឹទ្ធសភា បានចុះបំពេញបេសកកម្មទៅខេត្តក្រចេះ ខេត្តព្រះសីហនុ និងខេត្តកណ្តាល ដើម្បីស្វែងយល់អំពីការយល់ដឹង និងចាត់តាំងអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព គោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ ក្រុមមន្ត្រីចុះសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មាន និងជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំមន្ទីរពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ ។

**៤.ការងារអន្តរជាតិ៖**

-ទទួលជួបជាមួយសមាជិករដ្ឋសភាជប៉ុន ទីប្រឹក្សាស្ថានទូតជប៉ុន ក្រុមសំណង់ចិន និងក្រុមវិនិយោគិនជប៉ុន ។

-ទទួលដំណើរទស្សនកិច្ចសិក្សារបស់សាស្ត្រាចារ្យ និងនិស្សិតមកពីវិទ្យាស្ថាន**ខេមហ្វឹត** ចំនួន ៨៧នាក់ និងសាស្ត្រាចារ្យ និស្សិតនៃសាកលវិទ្យាល័យ Aix Marseille ប្រទេសបារាំង ចំនួន១៦នាក់។

-រៀបចំបែបបទជូនសមាជិកព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ លើកទី២២ វេទិកាសភាអាស៊ីប៉ាស៊ីហ្វិក APPF នៅទីក្រុង Puerto Vallarta ប្រទេសម៉ិកស៊ិក ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៥.ទំនាក់ទំនងសាធារណៈ៖**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានា

របស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៥៧៦នាក់ ។

**៦.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន០៣វគ្គ ស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សជំហាន២ វគ្គការងារ និងរបៀបនាំពាក្យ និងវគ្គវិជ្ជាជីវៈ ទំនាក់ទំនងសាធារណៈ ។

-មន្ត្រីចំនួន០៧នាក់ ទទួលអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ នៅតាមសាកលវិទ្យាល័យក្នុងប្រទេស ។

+ ការបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេស

-មន្ត្រីចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីភាពជាអ្នកដឹកនាំ នៅប្រទេសស្វីស និងមន្ត្រីចំនួន០២រូប ចូលរួមវគ្គ Advance Certificate in Web Design& Development at the Partech Ltd..., ០១រូបទៀត ចូលរួមវគ្គ Web Application& Development Using. Net at Centre For Development of Advanced Computing, Noida នៅប្រទេសឥណ្ឌា ។

-អាហារូបករណ៍ថ្នាក់បណ្ឌិត និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន០៨នាក់ នៅប្រទេសស្វីស ចិន និងវៀតណាម ។

**៧.ការអភិវឌ្ឍន៍ស្ថាប័ន៖**

-ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងបរិវេណព្រឹទ្ធសភា (ជួសជុលផ្លូវ របង ធ្វើសួនច្បារ តបណ្តាញអគ្គិសនី ទឹក ទូរស័ព្ទ បច្ចេកវិទ្យាព័ត៌មាន) ។

-ភាគីចិនកំពុងសិក្សាគំរោងសាងសង់អគារ១ខ្នង៣ជាន់ទៀត សម្រាប់ថ្នាក់ដឹកនាំបំពេញការងារ

-រដ្ឋសភាវៀតណាមឯកភាពផ្តល់ជំនួយបំពាក់ប្រព័ន្ធIT នៅក្នុងព្រឹទ្ធសភាកម្ពុជា (អនុវត្តចាប់ពីដើមឆ្នាំ២០១៤) ។

**៨. ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ពិធីសម្ពោធអាគារការិយាល័យចំនួន០៣ខ្នង កម្ពស់០៣ជាន់ ជាជំនួយរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ។

-ធ្វើជំរឿន និងរៀបចំតារាងបៀវត្សមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន សម្រាប់ឆ្នាំ២០១៤ ។

-រៀបចំគោលការណ៍ហិរញ្ញវត្ថុដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ សម្រាប់ប្រតិបត្តិឆ្នាំ២០១៤ និងរបាយការណ៍នៃលទ្ធផលនៃការប្រតិបត្តិហិរញ្ញវត្ថុ ឆ្នាំ២០១៣ ។

-ការរៀបចំរចនាសម្ព័ន្ធការងារ និងការផ្លាស់ប្តូរអគារធ្វើការក្នុងស្ថានភាពថ្មី ។

-មន្ត្រីរាជការបានចុះបេសកកម្មអមដំណើរគណៈប្រតិភូព្រឹទ្ធសភា ចំនួន០៤លើក ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន០៩លើក ។

-ថតចម្លងឯកសារ ចំនួន ១២៣សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន២៨ក្បាល ដោះស្រាយសំណើថវិកាចំនួន១៦៦សំណើ និងសម្ភារចំនួន៤៧សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន៩៤លើក ។

-ប្រគល់តុប្រជុំ តុការិយាល័យ ទូ កៅអី សាឡុង ម៉ាស៊ីនត្រជាក់ កុំព្យូទ័រ ម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីនហ្វូតូកូពី ម៉ាស៊ីនស្កាយ ក្បាលមេក្រូ ធុងបាស ទូទឹកកក ទូរស័ព្ទលើតុ និង ទូរទស្សន៍ ជាជំនួយរបស់រដ្ឋាភិបាលចិន ចំនួន១២២១គ្រឿង និងបិទលេខកូដកៅអី ចំនួន០៧គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ បន្ទប់ទឹក ដាក់ទុយោអនាម័យ ប្តូរអំពូល ព្រី កុងតាក់ ចំនួន១២៤គ្រឿង។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន៦៤គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៦៤ប្រធានបទ ។

## II.ទិសដៅការងារខែកុម្ភៈ ឆ្នាំ២០១៤

យកចិត្តទុកដាក់អនុវត្តគោលនយោបាយ១២ចំណុចដោយដាក់ស្តែង៖

១-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ដើម្បីធ្វើរបាយការណ៍ទូទាត់ថវិកា ឆ្នាំ២០១៣ និងគោលការណ៍ហិរញ្ញវត្ថុ ឆ្នាំ២០១៤ ។

២-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូជាតិ អន្តរជាតិ និងអង្គទូតនានា ។

៣-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

៤-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស (មហាសន្និបាត IPU-Geneva ខែមីនា, ទស្សនកិច្ចវៀតណាម ឡាវ ម៉ាឡេស៊ី ចិន ហុងគ្រី សហរដ្ឋអាមេរិក...)

៥-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

៦-សិក្សាលទ្ធភាពរៀបចំសិក្ខាសាលាស្តីពី "តំរូវការរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាមួយដៃគូជាតិ-អន្តរជាតិ និងសិក្ខាសាលាស្តីពីវិមជ្ឈការ និងវិសហមជ្ឈការរបស់គណៈកម្មការទី៤ (ខែមីនា) ។

៧-ជំរុញលើកកម្ពស់ចំណេះដឹង ការបើកវគ្គសិក្សាជំនាញ ភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន

និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

៨-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់៤អង្គភាពជាជំហានដំបូង ។

៩-ជំរឿនទ្រព្យសម្បត្តិរដ្ឋ និងការគិតគូរដល់ដំណើរការ ប្រព័ន្ធការងារ មធ្យោបាយ និងធនធាន សម្រាប់គ្រប់អង្គភាព ព្រមទាំងជីវភាព សុខុមាលភាព មន្រ្តីរាជការ តាមរបប៣៖ របបសន្តិសុខសង្គម របបធានារ៉ាប់រងសុខភាព និងរបបសោធននិវត្តន៍ ។

១០-ដាក់អនុវត្តការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន និងអនុវត្តការផ្ទេរទីកន្លែងធ្វើការរបស់នាយកដ្ឋាន និងអគ្គនាយកដ្ឋានតាមអគារ ។

១១-បន្តតាមដានគម្រោងសាងសង់អគារថ្មីជាមួយទីប្រឹក្សាពាណិជ្ជកម្មចិន ។

១២-បន្តពង្រឹងដំណើរការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញការចាប់ផ្តើមដំណើរការដោយស្វយ័តរបស់អង្គភាពលទ្ធកម្មសាធារណៈ និងអង្គភាពសវនកម្មផ្ទៃក្នុង ។ ធ្វើគម្រោងលទ្ធកម្មសាធារណៈ ឆ្នាំ២០១៤ និងដំណើរការអនុវត្ត ។

១៣-បន្តអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមកិច្ចសហប្រតិបត្តិការជាមួយវៀតណាម ចិន កូរ៉េ ឥណ្ឌា និងជប៉ុន (វៀតណាមនឹងចាប់សិក្សាក្នុងខែកុម្ភៈ ឆ្នាំ២០១៤) ។ ត្រៀមផលិតខ្សែវីដេអូសម្រាប់ខួបអនុស្សាវរីយ៍ ព្រឹទ្ធសភា នីតិកាលទី៣ ។

១៤-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

-កិច្ចសហប្រតិបត្តិការជាមួយ KOICA, JICA, CAMSERV, VN, ឥណ្ឌូនេស៊ី សឹង្ហបុរី ម៉ាឡេស៊ី កូរ៉េ CHINA BRUNEI វិទ្យាស្ថានធនាគារពិភពលោក វិទ្យាស្ថានសភាកម្ពុជា ។

១៥-រៀបចំចងក្រងប្រវត្តិព្រឹទ្ធសភា និងប្រវត្តិអគារក្រហម អគារ៤ខ្នង ជាជំនួយរបស់ចិន និងអគារ២ខ្នង ជាជំនួយរបស់ជប៉ុន ។ ធ្វើបច្ចុប្បន្នភាព និងថែរក្សាឯកសារសហប្រតិបត្តិការជាមួយដៃគូ ។

១៦-ជួសជុល និងកែលម្អសាលសិក្ខាសាលាខាងជើង និងខាងត្បូង និងរៀបចំសាលសិក្សា ព្រមទាំងបន្ទប់ប្រជុំការងារថ្មី ។

១៧-គិតគូរជំរុញការអភិវឌ្ឍន៍បណ្ណាល័យ និងបណ្ណសារដ្ឋាន ។

១៨-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារបច្ចុប្បន្នភាពរបស់ជាតិ ។

**III.សេចក្តីសន្និដ្ឋាន**

ឆ្នាំថ្មីនាំមកនូវសក្តានុពលថ្មី និងជោគជ័យថ្មី ។

ក្នុងខែមករានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបន្តសម័យប្រជុំពេញអង្គ លើកទី៤ ដោយបានពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០១ និងបានបញ្ចប់ការសាងសង់ ព្រមទាំងរៀបចំពិធីសម្ពោធអាគារ០៣ខ្នង ០៣ជាន់ និងការផ្លាស់ប្តូរកន្លែងធ្វើការរបស់គណៈកម្មការ និងនាយកដ្ឋាននានា ចំណុះអគ្គនាយកដ្ឋាន ។ ក្រៅពីនេះ បានត្រួតពិនិត្យមើលលើលទ្ធផលនៃការអនុវត្តសកម្មភាព របស់អគ្គនាយកដ្ឋានទាំងបី ព្រមទាំងធ្វើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភា ឆ្នាំ២០១៣ និងរៀបចំកំណត់គោលការណ៍ប្រតិបត្តិហិរញ្ញវត្ថុរបស់ព្រឹទ្ធសភាសម្រាប់ឆ្នាំ២០១៤ ដើម្បីដាក់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រឹទ្ធសភា ។ ដំណើរការសុខុដុមកម្ម និងប្រក្រតីកម្មការងារ និងបរិយាកាសនៅតែជាអាទិភាពខ្ពស់ ។ ទីកន្លែងធ្វើការ និងមធ្យោបាយការងារត្រូវបានពង្រីក និងបំពាក់បន្ថែម ក្នុងបរិមាណ និងគុណភាពមួយថ្មី ខ្ពស់ និងទូលាយជាងមុន ។ ដំណើរការរៀបចំត្រូវបន្តធ្វើក្នុងខែកុម្ភៈថែមទៀត ។ ការប្រឈមទាមទារឲ្យបង្ហាញនូវប្រសិទ្ធភាពថ្មី ប្រសិទ្ធផលថ្មី និងគុណភាពថ្មី ក្នុងការងារ ព្រមទាំងត្រូវខិតខំជំរុញការសន្សំសំចៃឲ្យបានខ្ពស់បំផុត ។

ភ្នំពេញ, ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៤

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ